# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
លេខ ១៧៧ ប្រក.កសក

**ក្រសួងបរិស្ថាន**
លេខ២០៦ ប្រក.បស្ថ

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** **រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣នស/៩៤ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មនៃច្បាប់ស្តីពី វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញបទបញ្ជាលេខ ០១បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលដៅពង្រឹងការអនុវត្តបទប្បញ្ញត្តិ និងបច្ចេកទេសនានា ដែលទាក់ទងនឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យគម្រោងទាំងអស់ធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

**ប្រការ២.-**

ក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍ ដែលមានដីសម្បទានទាំងអស់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំដូចខាងក្រោម៖

- គម្រោងវិនិយោគអភិវឌ្ឍរបស់ក្រុមហ៊ុន ត្រូវអនុវត្តតាមគោលនយោបាយរូបមន្តស្បែកខ្លា ដោយត្រូវធានាថា មិនធ្វើឱ្យប៉ះពាល់ដល់ដីធ្លីប្រើប្រាស់ អាស្រ័យផលរបស់ប្រជាជន ដីព្រៃសហគមន៍ និងដីអភិរក្សដែលត្រូវរក្សាទុក
- ក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល លើគម្រោងវិនិយោគអភិវឌ្ឍន៍ត្រូវបន្តអនុវត្តតាមគោលការណ៍បច្ចេកទេស និងនីតិវិធីច្បាប់ឱ្យបានឆាប់ ឈានដល់ការធ្វើផែនការមេ រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ការចុះកិច្ចសន្យា និងចុះបញ្ជីដីរដ្ឋ ដើម្បីដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងបរិស្ថានពិនិត្យ និងអនុម័ត

- បន្ទាប់ពីទទួលការឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ពីក្រសួងបរិស្ថានរួចហើយ ក្រុមហ៊ុនត្រូវធ្វើការស្នើសុំឈូសឆាយទៅតាមអនុតំបន់នីមួយៗ ស្របតាមផែនការមេសម្រាប់ការងារដាំដុះ។ ការឈូសឆាយនេះ ត្រូវធានារក្សាទុកតំបន់ដែលត្រូវអភិរក្សដូចជាតំបន់ទីជម្រាល ព្រៃស្រោង តំបន់ព្រៃដែលជាទីសក្ការះរបស់ប្រជាសហគមន៍មូលដ្ឋាន តំបន់ព្រៃកប់ខ្មោចរបស់ប្រជាពលរដ្ឋ តំបន់ព្រៃនៅតាមបណ្តោយអូរ ស្ទឹង បឹងបួរ ឬព្រែកយ៉ាងតិចប្រវែង១០០ម៉ែត្រ។ល។
- ក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតឱ្យធ្វើការឈូសឆាយពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬពីក្រសួងបរិស្ថាន ត្រូវសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីជំនាញតាមតំបន់សាមី និងអង្គភាពពាក់ព័ន្ធ ព្រមទាំងប្រជាសហគមន៍មូលដ្ឋាន។ ការឈូសឆាយនេះមិនត្រូវប៉ះពាល់ដល់ដីប្រើប្រាស់ អាស្រ័យផលរបស់ប្រជាពលរដ្ឋឡើយ។ ក្នុងករណីមានការតវ៉ាពីប្រជាពលរដ្ឋការឈូសឆាយត្រូវផ្អាក សកម្មភាពជាបន្ទាន់ ដើម្បីធ្វើការដោះស្រាយឱ្យបានចប់សព្វគ្រប់ ដោយឈរលើគោលការណ៍យុត្តិធម៌ត្រឹមត្រូវ មុននឹងចាប់ផ្តើម ឬបន្តការឈូសឆាយ
- មុននឹងសុំឈូសឆាយតំបន់ ឬអនុតំបន់ថ្មី ក្រុមហ៊ុនត្រូវធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃតំបន់ឬអនុតំបន់ដែលបានឈូសឆាយរួច ដើម្បីដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងបរិស្ថាន។ ក្រសួងនឹងរៀបចំក្រុមការងារចុះពិនិត្យជាក់ស្តែង ដើម្បីផ្ទៀងផ្ទាត់ជាមួយរបាយការណ៍របស់ក្រុមហ៊ុន ហើយធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីដើម្បីសុំការសម្រេចចំពោះតំបន់ ឬអនុតំបន់ដែលនឹងត្រូវសុំគោលការណ៍ឈូសឆាយ
- ក្រុមហ៊ុនត្រូវធានានូវការប្រមូលផល-អនុផលព្រៃឈើ ដែលទទួលបានពីការឈូសឆាយដីសម្រាប់អភិវឌ្ឍន៍ មកគរទុកតាមលក្ខណៈបច្ចេកទេស និងស្នើមកគណៈកម្មការអន្តរក្រសួង ដែលមានសមាសភាពមកពីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះពិនិត្យ វាស់វែង ផ្ទៀងផ្ទាត់ ជូនក្រុមហ៊ុនបង់ចំណូលចូលថវិការដ្ឋ។ ការប្រមូលផល-អនុផលព្រៃឈើនេះ ធ្វើឡើងតែក្នុងតំបន់ឈូសឆាយ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងបរិស្ថានបានអនុញ្ញាតតែប៉ុណ្ណោះ
- ក្រុមហ៊ុនត្រូវធានាថាមិនកាប់ឈើនៅក្នុងតំបន់អភិរក្ស និងតំបន់ខាងក្រៅទីតាំងសម្បទានដីរបស់ក្រុមហ៊ុន និងមិនប្រមូលទិញឈើខុសច្បាប់ពីតំបន់ខាងក្រៅមករក្សាទុក សម្រាប់ធ្វើអាជីវកម្មជាលក្ខណៈស្របច្បាប់នៅក្នុងទីតាំងក្រុមហ៊ុនឡើយ
- ក្រុមហ៊ុនត្រូវធានាថាមិនដុតបំផ្លាញឈើមានតម្លៃសេដ្ឋកិច្ច ដែលបានមកពីការឈូសឆាយ ដីក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច និងត្រូវធានាថាមិនទុកឈើឱ្យពុកផុយដោយមិនបានធ្វើការស្នើសុំមកក្រសួងឱ្យចុះត្រួតពិនិត្យ វាស់វែង និងផ្ទៀតផ្ទាត់ ដើម្បីបង់ចំណូលចូលថវិការដ្ឋ។ ប្រសិនបើក្រុមហ៊ុនពុំត្រូវការប្រើប្រាស់ផល-អនុផលព្រៃឈើទេ ត្រូវជូនដំណឹងមកក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ឬក្រសួងបរិស្ថាន ដើម្បីប្រកាសដាក់ដេញថ្លៃជាសាធារណៈស្របតាមនីតិវិធីច្បាប់

- ករណីមានដៃគូសហការប្រមូលផល-អនុផលព្រៃឈើ ក្រុមហ៊ុនដើមត្រូវធ្វើសំណើសុំឯកភាព និងទទួលស្គាល់ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងបរិស្ថាន ដោយក្រុមហ៊ុនដើមនៅតែត្រូវទទួលខុសត្រូវរួមជាដែល
- តំបន់គម្រោងវិនិយោគ ដែលត្រូវបានគណៈកម្មការអន្តរក្រសួងចុះត្រួតពិនិត្យ វាស់វែង និងផ្ទៀងផ្ទាត់ផល-អនុផលព្រៃឈើរួចហើយ ក្រុមហ៊ុនត្រូវរួសរាន់ទៅបង់សួយសារលើផល-អនុផលព្រៃឈើទាំងនោះ ដោយមិនត្រូវពន្យាពេលឡើយ។ ក្នុងករណីមិនចូលបង់សួយសារលើផល-អនុផលព្រៃឈើ ក្នុងរយៈពេលមួយខែ គិតចាប់ពេលបានទទួលលិខិតស្នើឱ្យទៅបង់សួយសារ ក្រុមហ៊ុននឹងត្រូវទទួលការព្រមានពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងបរិស្ថាន

**ប្រការ៣**.-

ចំពោះការស្នើសុំទីតាំង និងតម្លើងម៉ាស៊ីនកែច្នៃផល-អនុផលព្រៃឈើក្នុងតំបន់វិនិយោគ ដែលប្រមូលបានពីការឈូសឆាយក្នុងតំបន់វិនិយោគរបស់ក្រុមហ៊ុន សម្រាប់ការងារអភិវឌ្ឍដាំដំណាំកសិ-ឧស្សាហកម្ម និងទេសចរណ៍ធម្មជាតិ ក្រុមហ៊ុនត្រូវធ្វើកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងបរិស្ថាន ដែលមានសុពលភាពសម្រាប់រយៈពេលមួយឆ្នាំម្តង។

**ប្រការ៤**.-

គ្រប់សម្បទានដីសេដ្ឋកិច្ច ឬដីជួលរយៈពេលវែង ត្រូវមានការចុះបញ្ជីដីរដ្ឋ និងការធ្វើអនុប្រយោគជាដីឯកជនរបស់រដ្ឋ។ ចំពោះក្រុមហ៊ុនដែលពុំទាន់បានបំពេញលក្ខខណ្ឌទាំងនេះ ត្រូវចាត់ចែងធ្វើឱ្យបានឆាប់រហ័ស។

**ប្រការ៥**.-

ក្រុមហ៊ុនដែលដល់កាលកំណត់បង់ប្រាក់ថ្លៃសម្បទាន ឬថ្លៃឈ្នួល ត្រូវចាត់ចែងបង់ប្រាក់ទាំងនេះតាមកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។

**ប្រការ៦**.-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងបរិស្ថាន នឹងធ្វើការណែនាំដល់ក្រុមហ៊ុនវិនិយោគដែលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងកិច្ចសន្យា ឬគោលការណ៍បច្ចេកទេស និងច្បាប់នានា។ ក្នុងករណីដែលក្រុមហ៊ុននៅតែមិនអនុវត្តតាមទៀតនោះក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ឬក្រសួងបរិស្ថាននឹងលើកសំណើទៅរាជរដ្ឋាភិបាល ដើម្បីលុបចោល គម្រោងវិនិយោគអភិវឌ្ឍន៍នោះ។

**ប្រការ៧.-**

រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន ត្រូវទទួលខុសត្រូវតាមដាន ត្រួតពិនិត្យ និងសហការឱ្យបានល្អជាមួយអង្គភាពពាក់ព័ន្ធក្នុងការអនុវត្តប្រកាសអន្តរក្រសួងនេះ ប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៨.-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ប្រធានមន្ទីរកសិកម្ម និងប្រធានមន្ទីរបរិស្ថាន ព្រមទាំងអាជ្ញាធររាជធានី-ខេត្ត និងក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍ដែលមានដីសម្បទានទាំងអស់ ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ[illegible]ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

***កន្លែងទទួល៖***

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-សាលារាជធានី ខេត្ត*
*-ដូចប្រការ៨*
*-រាជកិច្ច*
*-ឯកសារ កាលប្បវត្តិ*